ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
អគ្គនាយកដ្ឋានពន្ធដារ
លេខ ១៣៣៤៧ អពដ

រាជធានីភ្នំពេញ, ថ្ងៃទី ១៥ ខែសីហា ឆ្នាំ២០១៦

# សេចក្តីជូនដំណឹង
## ស្តីពី
## ការពន្យារកាលបរិច្ឆេទកំណត់ឱ្យដាក់លិខិតប្រកាសពន្ធ និងបង់ប្រាក់ពន្ធ-អាករ សម្រាប់ការិយបរិច្ឆេទជាប់ពន្ធប្រចាំខែកក្កដា ឆ្នាំ២០១៦

អគ្គនាយកដ្ឋានពន្ធដារ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មានកិត្តិយសសូមជម្រាបជូនដំណឹងដល់អ្នកជាប់ពន្ធ និងសាធារណៈជនទាំងអស់ឲ្យបានជ្រាបថា ដោយសារអ្នកជាប់ពន្ធភាគច្រើនទៅបង់ប្រាក់ពន្ធនៅធនាគារក្នុងថ្ងៃជិតផុតរយៈពេលនៃការបង់ប្រាក់ពន្ធសម្រាប់ខែកក្កដា ឆ្នាំ២០១៦ ដែលជាហេតុធ្វើឱ្យធនាគារទទួលប្រាក់ពន្ធរបស់អ្នកជាប់ពន្ធមិនទាន់ពេលវេលា។ ដូចនេះ អគ្គនាយកដ្ឋានពន្ធដារសម្រេចពន្យារកាលបរិច្ឆេទកំណត់ឲ្យដាក់លិខិតប្រកាសពន្ធ និងបង់ប្រាក់ពន្ធ-អាករគ្រប់ប្រភេទ លើកលែងតែអាករលើតម្លៃបន្ថែម ប្រចាំខែកក្កដា ឆ្នាំ២០១៦ រហូតដល់ **ថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៦**។ សម្រាប់ខែបន្តបន្ទាប់ត្រូវអនុវត្តជាធម្មតាដូចមានចែងក្នុងលិខិតជូនដំណឹងលេខ ១០៨៧ អពដ ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៣ ។

អគ្គនាយកដ្ឋានពន្ធដារ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសង្ឃឹមជឿជាក់ថា ការពន្យារកាលបរិច្ឆេទដាក់លិខិតប្រកាស និងបង់ប្រាក់ពន្ធ-អាករ នេះនឹងជួយសម្រួលដល់អ្នកជាប់ពន្ធទាំងអស់ ក្នុងការបំពេញកាតព្វកិច្ចសារពើពន្ធជាក់ជាពុំខាន។

ប្រតិភូរាជរដ្ឋាភិបាល
ទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ

Collection by VCAT Professional Consultant

គុំ សីហា